# លិខិតអញ្ជើញ ចូលរួមដេញថ្លៃ

១. អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ សូមគោរពអញ្ជើញ ក្រុមហ៊ុន ឬឯកត្តបុគ្គល ទាំងអស់ដែលមានបំណង ដើម្បីចូលរួមដេញថ្លៃសាងសង់អគារសិក្សាមួយខ្នងដែលមាន ០៥បន្ទប់ នៅ**សាលាបឋមសិក្សាកំពង់ពោធិ៍** ដែលស្ថិតនៅ **ភូមិកំពង់ពោធិ៍, ឃុំកំពង់ស្រឡៅមួយ, ស្រុកឆែប, ខេត្តខេត្តព្រះវិហារ សាលាបឋមសិក្សាថ្នល់ដាច់ ដែលស្ថិតនៅ ភូមិថ្នល់ដាច់, ឃុំលំទង, ស្រុកអន្លង់វែង, ខេត្តឧត្តរមានជ័យ និងសាលាបឋមសិក្សាបន្ទាយជ័រ ដែលស្ថិតនៅ ភូមិបន្ទាយជ័រ, ឃុំពង្រ, ស្រុកចុងកាល់, ខេត្តឧត្តរមានជ័យ** ដែលកំណត់រយៈពេលសាងសង់ ចំនួន **២១០ ថ្ងៃ** ដោយរាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក និងបុណ្យជាតិ-អន្តរជាតិផ្សេងៗ ។

២. ក្រុមហ៊ុន ឬឯកត្តបុគ្គលអាចចូលរួមដេញថ្លៃ ជាមួយយើងខ្ញុំបាន ដោយគ្រាន់តែ**ទាញយក និងបំពេញតាមលក្ខណដែលបានកំណត់ក្នុងឯកសារដេញថ្លៃដូចក្នុងតំណភ្ជាប់** ៖ https://www.acledabank.com.kh/assets/download-file/?name=AJF-Bid-Document-2022-2023&extn=rarwebc4f97cce9dfbca29d7ec9fc535019646cd1556d1468701ff1aebcdfa190bf6e5

**លេខសម្ងាត់៖ Wr%549&Fum** រួចផ្ញើមកលោក **មាស សុជាតិ លេខទូរសព្ទ ០១០ ៤៧៧ ៤៧៩, អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ជាឯកសារច្បាប់ដើមពីរច្បាប់ និងផ្នែកទន់ (PDF រួមទាំង BOQ excel version) ជា CD or USB ដែលគ្មានមេរោគ** (ករណីដែលមានមេរោគឯកសារដេញថ្លៃនោះត្រូវមោឃភាពដោយស្វ័យប្រវត្តិ) **ត្រឹមម៉ោង ១៦:០០នាទីល្ងាច ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣** ដោយមានការបិទជិតបានត្រឹមត្រូវ ។

**សម្គាល់៖** អង្គការមិនទទួលយកឯកសារដេញថ្លៃណា ដែលហួសពេលកំណត់ ដោយឥតលក្ខខណ្ឌឡើយ។ ឯកសារដេញថ្លៃដែលបានផ្ញើមកហើយ មិនអាចប្រគល់ត្រឡប់វិញទេ ។

៣. ការជ្រើសរើសក្រុមហ៊ុន ឬឯកត្តបុគ្គលដែលមានតម្លៃ និងគុណសម្បត្តិគ្រប់គ្រាន់ សម្រាប់សាងសង់ទាំងបី ឬពីរ ឬមួយសាលា នឹងត្រូវវាយតម្លៃ និងផ្តល់អនុសាសន៍ ដោយគណៈកម្មាធិការគ្រប់គ្រងគម្រោង និងអនុមតិដោយប្រធានអង្គការ ត្រឹម**ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣** ។

៤. យើងខ្ញុំសង្ឃឹមថា ក្រុមហ៊ុន ឬឯកត្តបុគ្គលចូលរួមដេញថ្លៃ នឹងមិនមានអំពើពុករលួយ ក្លែងបន្លំ បង្ខិតបង្ខំ បំពាន ឬធ្វើឲ្យរាំងស្ទះអ្វីមួយក្នុងកំឡុងពេលដេញថ្លៃ ចុះកុងត្រា និងពេលសាងសង់ ជាដើម ។

៥. អេស៊ីលីដា-ចារឌីន រង់ចាំទទួលឯកសារដេញថ្លៃដែលមានលក្ខណៈគ្រប់គ្រាន់ពីក្រុមហ៊ុន ឬឯកត្តបុគ្គលទាំងអស់។ ជាថ្មីម្តងទៀតសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទុកជាមុនសម្រាប់ការចូលរួមដេញថ្លៃជាមួយយើងខ្ញុំ ។

**ប្រធានគណៈកម្មាធិការគ្រប់គ្រងគម្រោង**

**ពៅ ទិត្យមិថុនា**

សូមអរគុណ!